**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករទូរគមនាគមន៍កម្ពុជា**

លេខ : ០១៧៩ ន.ទ.ក.

# សេចក្តីណែនាំ
# ស្តីពី
# ការស្នើសុំលិខិតអនុញ្ញាតបើកលក់ និង/ឬ ជួសជុល គ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ នៅក្នុងរាជធានីភ្នំពេញ

និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) មានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា៖ អនុលោមតាមច្បាប់ស្តីពីទូរគមនាគមន៍ បុគ្គលទាំងឡាយជាជនជាតិខ្មែរ ឬ ជនជាតិបរទេស ដែលចង់បំពេញប្រតិបត្តិការទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចមានកំណត់នៅក្នុងចំណុច "គ" មាត្រា ១៥ នៃច្បាប់នេះ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតពី ន.ទ.ក.។ ដូច្នេះដើម្បីបង្កើនភាពងាយស្រួលដល់អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ន.ទ.ក. សូមធ្វើការណែនាំអំពីនីតិវិធី និង ឯកសារតម្រូវដូចខាងក្រោម៖

## ក. សេវា

- លិខិតអនុញ្ញាតបើកលក់ និង/ឬ ជួសជុលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ នៅក្នុងរាជធានីភ្នំពេញ

## ខ. ស្ថាប័នផ្តល់សេវា

និយ័តករទូរគមនាគមន៍កម្ពុជា៖

ក្នុងករណីដាក់ពាក្យដោយផ្ទាល់៖

- បញ្ជរអតិថិជន (ផ្នែកប្រឹក្សាព័ត៌មាន ទទួលពាក្យ បង់ប្រាក់ និងទទួលលិខិតអនុញ្ញាត)
- អាសយដ្ឋាន៖ អគារ ន.ទ.ក. វិថីលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
    - ទូរសព្ទ៖ ១២៧២ ឬ ០២៣ ៧២ ២៣ ៣៣
    - ទូរសារ៖ ០២៣ ៧២ ៣២ ២២
    - អ៊ីមែល៖ frontdesk@trc.gov.kh

ក្នុងករណីដាក់ពាក្យដោយប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម៖

- គេហទំព័រ៖ www.trc.gov.kh/online

## គ. គោលបំណងនៃការផ្តល់សេវា

បង្កើនភាពងាយស្រួលដល់សាធារណជន ក្នុងការស្នើសុំលិខិតអនុញ្ញាត ដើម្បីបំពេញប្រតិបត្តិការក្នុងវិស័យទូរគមនាគមន៍នៅក្នុងប្រទេសកម្ពុជា ព្រមទាំងជានាការគ្រប់គ្រងហាងលក់ និង/ឬ ជួសជុលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍នៅក្នុងរាជធានីភ្នំពេញ ឱ្យមានប្រសិទ្ធភាព និងជានាលើការប្រើប្រាស់បរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។

## ឃ. មូលដ្ឋានគតិយុត្ត

- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍



វិថីលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
(855) 23 72 23 33
(855) 23 72 32 22
info@trc.gov.kh
www.trc.gov.kh

- ប្រកាសលេខ ១២២ បទ.ប្រក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និង ការដកហូត លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍
- ប្រកាសរួមលេខ៤៩៩ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈរបស់និយ័តករទូរគមនាគមន៍កម្ពុជា ។

## ខ. អតិថិជនដែលមានសិទ្ធិទទួលសេវា

ជនជាតិខ្មែរ ឬ ជនបរទេស ជារូបវន្តបុគ្គល ឬ នីតិបុគ្គល។

## ច. ស្តង់ដាសេវា

### ១. រយៈពេលផ្តល់សេវា

- ១០ ថ្ងៃ (ថ្ងៃធ្វើការ) សម្រាប់ការពិនិត្យ វាយតម្លៃ និងសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាត បន្ទាប់ពីអ្នកស្នើសុំបានបំពេញពាក្យស្នើសុំត្រឹមត្រូវ និងផ្តល់ឯកសារគ្រប់គ្រាន់។

### ២. កម្រៃ

អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតត្រូវបង់៖

- កម្រៃទទួល និងពិនិត្យពាក្យស្នើសុំបើកថ្មី ឬបន្តសុពលភាព ឬប្តូរទីតាំង ចំនួន ២០.០០០ (ម្ភៃពាន់) រៀល ។
- កម្រៃលិខិតអនុញ្ញាត (១ឆ្នាំ) ចំនួន ២០០.០០០ (ពីររយពាន់) រៀល។

ចំពោះការផ្តល់លិខិតអនុញ្ញាតសម្រាប់ឆ្នាំដំបូង ការយកកម្រៃសេវាត្រូវគិតតាមរយៈពេលនៅសល់ក្នុងឆ្នាំ យោងតាមកាលបរិច្ឆេទចុះហត្ថលេខាលើលិខិតអនុញ្ញាតរបស់ ន.ទ.ក. ដូចខាងក្រោម ៖

- រយៈពេលនៅសល់មិនលើស ៦ខែ ត្រូវគិតកម្រៃ ៥០% (ហាសិបភាគរយ) នៃកម្រៃប្រចាំឆ្នាំ
- រយៈពេលនៅសល់លើសពី ៦ខែ ត្រូវគិតកម្រៃពេញមួយឆ្នាំនៃកម្រៃប្រចាំឆ្នាំ។

## ឆ. ឯកសារតម្រូវដើម្បីទទួលបានសេវា

▪ អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ត្រូវបំពេញពាក្យសុំដូចមានគំរូនៅក្នុងឧបសម្ព័ន្ធទី១ និង ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ សៀវភៅគ្រួសារ ឬ លិខិតឆ្លងដែនមានសុពលភាព..០១ ច្បាប់
- ច្បាប់ចម្លងបណ្ណប៉ាតង់..........................................................................០១ ច្បាប់
- លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងបើកអាជីវកម្ម និង កិច្ចសន្យាជួលទីតាំងបើកអាជីវកម្ម មានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ក្នុងករណីជួលទីតាំង).......០១ ច្បាប់

▪ ក្នុងករណីអ្នកស្នើសុំដែលបានទទួលលិខិតអនុញ្ញាតការបើកលក់ និង/ឬ ជួសជុលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ មានបំណងចង់ផ្លាស់ប្តូរអាសយដ្ឋានហាង ត្រូវដាក់ពាក្យសុំដូចមានគំរូក្នុងឧបសម្ព័ន្ធទី២ និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- លិខិតអនុញ្ញាតការបើកលក់ និង/ឬ ជួសជុល ចាស់..........................................................០១ ច្បាប់
- លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងបើកអាជីវកម្ម និង កិច្ចសន្យាជួលទីតាំងបើកអាជីវកម្ម មានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ក្នុងករណីជួលទីតាំង).......០១ ច្បាប់

▪ ក្នុងករណីអ្នកស្នើសុំមានបំណងចង់បន្តអាជីវកម្ម ឬបន្តលិខិតអនុញ្ញាត ត្រូវដាក់ពាក្យសុំដូចមានគំរូក្នុងឧបសម្ព័ន្ធទី៣ ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃមុនលិខិតអនុញ្ញាតអស់សុពលភាព និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- លិខិតអនុញ្ញាតការបើកលក់ និង/ឬ ជួសជុល ចាស់.................................................. ០១ ច្បាប់

▪ ក្នុងករណីអ្នកស្នើសុំមានបំណងចង់បញ្ឈប់អាជីវកម្ម ឬលុបលិខិតអនុញ្ញាត ត្រូវដាក់ពាក្យសុំដូចមានគំរូក្នុងឧបសម្ព័ន្ធទី៤ ឱ្យបានមុន ៣០ (សាមសិប) មុនលិខិតអនុញ្ញាតអស់សុពលភាព និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- លិខិតអនុញ្ញាតការបើកលក់ និង/ឬ ជួសជុល ចាស់...............................................០១ ច្បាប់

ក្នុងករណីផ្លាស់ប្តូរនាមករណ៍ម្ចាស់ ឬហាងលក់ និង/ឬ ជួសជុល អ្នកស្នើសុំត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតថ្មី។

## ង. លក្ខខណ្ឌ

អ្នកកាន់លិខិតអនុញ្ញាតត្រូវអនុវត្តដូចតទៅ៖

១. ត្រូវគោរពឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិដូចមានចែងក្នុងចំណុច (**ឃ**) និង លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតដែលនៅជាធរមាន។

២. ត្រូវអនុវត្តស្របតាមលិខិតអនុញ្ញាត និងមិនត្រូវប្រើប្រាស់ហាងលក់ និង/ឬ ជួសជុលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ ជាទីតាំងសម្រាប់បង្កផលប៉ះពាល់ដល់សន្តិសុខជាតិ ដែលត្រូវហាមឃាត់ដោយច្បាប់ និងបទប្បញ្ញត្តិ ពាក់ព័ន្ធនានានៃព្រះរាជាណាចក្រកម្ពុជា។

៣. ត្រូវដាក់តាំងបង្ហាញលិខិតអនុញ្ញាតនេះនៅកន្លែងធ្វើអាជីវកម្ម។

៤. មិនត្រូវដាក់បញ្ចូលលេខហ្វ្រេកង់ស៍ឱ្យអ្នកប្រើប្រាស់វិទ្យុទាក់ទងដោយគ្មានការអនុញ្ញាតពី ន.ទ.ក.។ ចំពោះការបំពាក់អង់តែនវិទ្យុគ្រប់ប្រភេទសម្រាប់ធ្វើការសាកល្បងត្រូវមានការត្រួតពិនិត្យពីមន្ត្រីបច្ចេកទេស ន.ទ.ក. និងត្រូវមានលិខិតអនុញ្ញាតដោយឡែកពី ន.ទ.ក.។

៥. រាល់ការផ្ទេរ បន្ត ឬ បោះបង់ចោល(ឈប់ប្រតិបត្តិការ)លិខិតអនុញ្ញាត ត្រូវសុំការអនុញ្ញាតជាមុនពី ន.ទ.ក.។

៦. ករណីលិខិតអនុញ្ញាតផុតសុពលភាពឬលិខិតអនុញ្ញាតមានសុពលភាពនៅសល់តិចជាង ៣០ (សាមសិប) ថ្ងៃ អ្នកស្នើសុំដែលមានបំណងបន្តអាជីវកម្មត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតថ្មី ។

៧. ករណីផ្លាស់ប្តូរអាសយដ្ឋានហាង សុពលភាពនៃលិខិតអនុញ្ញាតថ្មីត្រូវគិតតាមសុពលភាពនៃលិខិតអនុញ្ញាតដែលបានផ្តល់ជូនសម្រាប់ទីតាំងហាងចាស់ ។

៨. ត្រូវចូលរួមអនុវត្តតាមការណែនាំរបស់មន្ត្រីត្រួតពិនិត្យនៃ ន.ទ.ក.។

៩. ក្នុងករណីអនុវត្តផ្ទុយពីសេចក្តីណែនាំនេះ អ្នកទទួលលិខិតអនុញ្ញាត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ថ្ងៃ អង្គារ ៩ រោច ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៩

**ប្រធាន**

TELECOMMUNICATION REGULATOR OF CAMBODIA

**ម៉ុង ចរិយា**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

"ដើម្បីជូនជ្រាប"

-គ្រប់សមាជិក - នាយកដ្ឋាន - អង្គភាព

ក្រោមឱវាទនិយ័តករទូរគមនាគមន៍កម្ពុជា

"ដើម្បីអនុវត្ត"

-ឯកសារ -កាលប្បវត្តិ